**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤៤៣ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៣.០១៣,៦៣៨៩ ហិកតា នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co,LTD និងកាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន PHEAPIMEX FUCHAN CAMBODIA Co,LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ១០៨ស.ត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្ទឹងត្រែង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៣.០១៣,៦៣៨៩ ហិកតា ក្នុងនោះ (១) ទំហំ ៣.០០៣,១២៥៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co., LTD និង (២) ទំហំ ១០,៥១៣៤ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន PHEAPIMEX FUCHAN Co., LTD និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ២.៤០២,០២៤៦ ហិកតា សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៦១១,៦១៤៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅឃុំស្រែសំបូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ដែលស្ថិតក្នុងភូមិដូចខាងក្រោម ៖

-កាត់ផ្ទៃដីទំហំ ៣៣៨,៨៥៣៨ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co,LTD ដែលទំហំ ២២៣,៩៣៨៨ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១១៤,៩០៥០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិណាអ្វង

-កាត់ផ្ទៃដីទំហំ ១៨៣,៩៣៨៣ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co,LTD ដែលទំហំ ១៣៩,១៧៤១ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤៤,៧៦៤២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិសំរោង

-កាត់ផ្ទៃដីទំហំ ៦៨១,២៥៧៣ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co,LTD ដែលទំហំ ៥៦២,៤២៩៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១១៨,៨២៧៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋនៅភូមិកញ្ចាញគោក

-កាត់ផ្ទៃដីទំហំ ៧៣៨,៩៨៨៧ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co,LTD ដែលទំហំ ៦២៤,៧៨៤៧ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១១៤,១៦៤០ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្រែឫស្សី

-កាត់ផ្ទៃដីទំហំ ២៣៣,៧១៧៥ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co,LTD ដែលទំហំ ១៦៥,៦១៣៦ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦៨,១០៣៩ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិកេតមឿង

-កាត់ផ្ទៃដីទំហំ ៤២២,៩២៩៨ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co,LTD ដែលទំហំ ៣៦២,៦០៧៧ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៦០,៣២២១ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិពាមខិះ

-កាត់ផ្ទៃដីសរុបទំហំ ៤១៤,០០៣៥ ហិកតា ក្នុងនោះ (១) ទំហំ ៤០៣,៤៩០១ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន GREEN SEA INDUSTRY Co., LTD និង (២) ទំហំ ១០,៥១៣៤ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន PHEAPIMEX FUCHAN Co., LTD ដែលទំហំ ៣២៣,៤៧៦២ ហិកតា សម្រាប់ធ្វើប្រទានកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៩០,៥២៧៣ ហិកតារក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិកញ្ចាញទឹក

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) (២) និង (៣) នៃអនុក្រឹត្យនេះ ។

**មាត្រា ២:** ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្ទឹងត្រែង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅឃុំស្រែសំបូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ។

**មាត្រា ៣:** ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ១.៦០១ ក្បាលដី ជូនប្រជាពលរដ្ឋ ៨៤២ គ្រួសារ នៅឃុំស្រែសំបូរ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ក្នុងនោះ ៖

- ១៥៥ ក្បាលដី ផ្តល់ជូនប្រជាពលរដ្ឋ ១០០ គ្រួសារ នៅភូមិណាអុង
- ៩០ ក្បាលដី ផ្តល់ជូនប្រជាពលរដ្ឋ ៥៥ គ្រួសារ នៅភូមិសំពោង
- ៤៧១ ក្បាលដី ផ្តល់ជូនប្រជាពលរដ្ឋ ២០០ គ្រួសារ នៅភូមិកញ្ចាញគោក
- ២២៧ ក្បាលដី ផ្តល់ជូនប្រជាពលរដ្ឋ ១៥២ គ្រួសារ នៅភូមិស្រែឬស្សី
- ១៣១ ក្បាលដី ផ្តល់ជូនប្រជាពលរដ្ឋ ៦២ គ្រួសារ នៅភូមិកេតមឿង
- ២៧០ ក្បាលដី ផ្តល់ជូនប្រជាពលរដ្ឋ ១៣៩ គ្រួសារ នៅភូមិពាមខិះ
- ២៥៧ ក្បាលដី ផ្តល់ជូនប្រជាពលរដ្ឋ ១៣៤ គ្រួសារ នៅភូមិកញ្ចាញទឹក ។

**មាត្រា ៤:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តស្ទឹងត្រែង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥:** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*